## សាលាកបត្រព័ត៌មានស្តីពីថ្នាំបង្ការ

# ថ្នាំបង្ការជំងឺគ្រុនផ្តាសាយ (អសកម្ម ឬrecombinant)

***ព័ត៌មានដែលលោកអ្នកត្រូវយល់ដឹង***

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis

ព័ត៌មានស្តីពីថ្នាំបង្ការមានជាភាសាអេស្ប៉ាញនិងភាសាដទៃទៀត។ សូមចូលទៅ www.immunize.org/vis

## 1 ហេតុអ្វីត្រូវទទួលថ្នាំបង្ការ?

ជំងឺគ្រុនផ្តាសាយ គឺជាជំងឺឆ្លង ដែលរាលដាលពេញសហរដ្ឋអាមេរិក រៀងរាល់ឆ្នាំ ដែលជាធម្មតា រវាងខែតុលា ដល់ខែឧសភា។

ជំងឺគ្រុនផ្តាសាយបង្កឡើងដោយមេរោគជំងឺគ្រុនផ្តាសាយ ហើយឆ្លងជាចម្បងតាមរយៈ ការក្អក កណ្តាស់ និងការប៉ះពាល់។

អ្នករាល់គ្នាអាចឆ្លងគ្រុនផ្តាសាយ។ ជំងឺគ្រុនផ្តាសាយកើតឡើងមួយរំពេច ហើយឈឺរយៈពេលច្រើនថ្ងៃ។ រោគសញ្ញាប្រែប្រួលតាមអាយុ ប៉ុន្តែអាចរួមមាន៖

- គ្រុនក្តៅ/រងា
- ឈឺបំពង់ក
- ឈឺសាច់ដុំ
- ណឿយហត់
- ក្អក
- ឈឺក្បាល
- ហៀរសំបោរ ឬតឹងច្រមុះ

ជំងឺគ្រុនផ្តាសាយក៏អាចបណ្តាលឲ្យកើតរោគរលាកសួតនិងជំងឺឈាម ហើយបណ្តាលឲ្យកុមារកើតរោគរាគ និងប្រកាច់។ ប្រសិនបើអ្នកមានបញ្ហាជំងឺ ដូចជា ជំងឺបេះដូង ឬជំងឺសួត ជំងឺគ្រុនផ្តាសាយអាចធ្វើឲ្យជំងឺនោះកាន់តែធ្ងន់ធ្ងរ។

ជំងឺគ្រុនផ្តាសាយអាចបង្កគ្រោះថ្នាក់ថែមទៀតចំពោះមនុស្សមួយចំនួន។ កូនក្មេង និងកុមារ មនុស្សចាស់អាយុ 65 ឆ្នាំឡើង ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានបញ្ហាសុខភាពមួយចំនួន ឬប្រព័ន្ធស៊ាំចុះខ្សោយ គឺជាអ្នកដែលហានិភ័យខ្ពស់បំផុត។

ក្នុងមួយឆ្នាំៗ **មនុស្សរាប់ពាន់នាក់នៅសហរដ្ឋអាមេរិកស្លាប់ដោយសារជំងឺគ្រុនផ្តាសាយ** ហើយមនុស្សជាច្រើននាក់ទៀតត្រូវចូលដេកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។

**ថ្នាំបង្ការជំងឺគ្រុនផ្តាសាយ** អាច៖

- ការពារអ្នកកុំឲ្យកើតជំងឺគ្រុនផ្តាសាយ
- ធ្វើឲ្យជំងឺគ្រុនផ្តាសាយមិនសូវធ្ងន់ធ្ងរ ប្រសិនបើអ្នកកើតជំងឺនេះ និង
- ការពារអ្នកកុំឲ្យចម្លងជំងឺគ្រុនផ្តាសាយដល់គ្រួសាររបស់អ្នក និងអ្នកដទៃទៀត។

## 2 ថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ដែលមេរោគអសកម្ម និង recombinant

គេណែ នាំឲ្យទទួលនូវថ្នាំបង្ការជំងឺគ្រុនផ្តាសាយចំនួនមួយដូស រៀងរាល់រដូវជំងឺគ្រុនផ្តាសាយ។ កុមារដែលមានអាយុ 6 ខែ ដល់ 8 ឆ្នាំ អាចត្រូវការថ្នាំបង្ការចំនួនពីរដូស ក្នុងអំឡុងរដូវជំងឺគ្រុនផ្តាសាយតែមួយ។ អ្នកដទៃផ្សេងទៀតត្រូវការតែមួយដូសប៉ុណ្ណោះ ក្នុងរដូវជំងឺគ្រុនផ្តាសាយនីមួយៗ។

ថ្នាំបង្ការជំងឺគ្រុនផ្តាសាយដែលមានមេរោគអសកម្ម មានសារធាតុបារ៉ត ដែលគេហៅថា សារធាតុធីមីរ៉ូសល (thimerosal) ក្នុងបរិមាណតិចបំផុត។ ការសិក្សាមិនបានបង្ហាញថាសារធាតុ ធីមីរ៉ូសល ក្នុងថ្នាំបង្ការ បង្កគ្រោះថ្នាក់ទេ ប៉ុន្តែ ក៏មានថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ដែលគ្មានសារធាតុធីមីរ៉ូសលដែរ។

ពុំមានមេរោគនៅរស់ ក្នុងថ្នាំបង្ការជំងឺគ្រុនផ្តាសាយទេ។ **មេរោគទាំងនោះមិនអាចបង្កជំពីគ្រុនផ្តាសាយទេ**។

មានមេរោគជំងឺគ្រុនផ្តាសាយជាច្រើន ហើយមេរោគទាំងនេះតែងតែប្រែប្រួលជានិច្ច។ រៀងរាល់ឆ្នាំ ថ្នាំបង្ការជំងឺគ្រុនផ្តាសាយថ្មី ត្រូវបានផលិតឡើង ដើម្បីការពារប្រឆាំងនឹងមេរោគចំនួន 3 ឬបួនប្រភេទ ដែលអាចបង្កជំងឺ ក្នុងរដូវជំងឺគ្រុនផ្តាសាយខាងមុខ។ ប៉ុន្តែ សូម្បីតែថ្នាំបង្ការមិនត្រូវចំមេរោគទាំងនេះក៏ដោយ ក៏ប៉ុន្តែ ថ្នាំបង្ការនៅតែអាចផ្តល់នូវការការពារមួយចំនួន។

វ៉ាក់សាំងផ្តាសាយមិនអាចបង្ការ:

- ជំងឺផ្តាសាយដែលបង្កឡើងដោយវីរុសមួយដែលមិនគ្របដណ្តប់ដោយការចាក់វ៉ាក់សាំងនេះ, ឬ
- ជំងឺដែលមើលទៅដូចជំងឺផ្តាសាយប៉ុន្តែមិនមានជំងឺផ្តាសាយ។

ត្រូវការពេលវេលាប្រហែល 2 សប្តាហ៍ ដើម្បីឲ្យប្រព័ន្ធការពារអភិវឌ្ឍ បន្ទាប់ពីបានទទួលនូវថ្នាំបង្ការ ហើយប្រព័ន្ធការពារមានប្រសិទ្ធិភាព ក្នុងអំឡុងរដូវជំងឺគ្រុនផ្តាសាយទាំងមូល។

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាំបង្ការនេះទេ

សូមប្រាប់អ្នកផ្តល់ថ្នាំបង្ការដល់អ្នក៖

- **ប្រសិនបើអ្នកមានអាឡាក់ស៊ីធ្ងន់ធ្ងរដែលគំរាមដល់អាយុជីវិត** ។ ប្រសិនបើលោកអ្នកមានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិត បន្ទាប់ទទួលថ្នាំបង្ការជំងឺគ្រុនផ្តាសាយមួយដូស ឬមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរចំពោះសារធាតុណាមួយនៃថ្នាំបង្ការ អ្នកមិនគួរទទួលថ្នាំបង្ការទេ។ ថ្នាំបង្ការប្រភេទភាគច្រើន ប៉ុន្តែមិនគ្រប់ប្រភេទទេ ដែលមានប្រូតេអ៊ីនស៊ុតក្នុងបរិមាណតិច។
- **ប្រសិនបើលោកអ្នកធ្លាប់មានជំងឺ Guillian-Barré (ជាជំងឺខ្វិនធ្ងន់ធ្ងរ ហៅថា ជំងឺ GBS)។**
  មនុស្សមួយចំនួន ដែលធ្លាប់មានជំងឺ GBS នេះ មិនគួរទទួលថ្នាំបង្ការនេះទេ។ គួរពិភាក្សាពីចំណុចនេះជាមួយនឹងវេជ្ជបណ្ឌិតរបស់អ្នក។
- **ប្រសិនបើលអ្នកមានអារម្មណ៍មិនសូវស្រួលខ្លួន។**
  ជាធម្មតា ការទទួលថ្នាំបង្ការមិនអីទេ នៅពេលអ្នកមានជំងឺស្រាល ប៉ុន្តែគេអាចស្នើឲ្យអ្នកមកវិញម្តងទៀត នៅពេលដែលអ្នកមានអារម្មណ៍ល្អប្រសើរជាងមុន។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 គ្រោះថ្នាក់នៃប្រតិកម្មនឹងថ្នាំបង្ការ

ដូចថ្នាំដទៃទៀតដែរ ដែលរួមទាំងថ្នាំបង្ការ អាចមានប្រតិកម្ម។ ជាធម្មតា ប្រតិកម្មទាំងនេះមានលក្ខណៈស្រាល ហើយបាត់ទៅវិញដោយឯកឯង ប៉ុន្តែ ក៏អាចមានប្រតិកម្មធ្ងន់ធ្ងរដែរ។

មនុស្សភាគច្រើន ដែលទទួលថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ពុំមានបញ្ហាជាមួយនឹងថ្នាំបង្ការទេ។

**បញ្ហាស្រាល** បន្ទាប់ពីចាក់ថ្នាំបង្ការ រួមមាន៖

- ឈឺ ឡើងក្រហម ឬហើម នៅកន្លែងចាក់ថ្នាំ
- សំឡេងស្អក
- ឈឺភ្នែក ភ្នែកក្រហម ឬរមាស់
- ក្អក
- គ្រុនក្តៅ
- ឈឺចាប់
- រមាស់
- អស់កម្លាំង

ប្រសិនបើបញ្ហាទាំងនេះកើតឡើង ជាធម្មតា បញ្ហាទាំងនេះកើតឡើងភ្លាម បន្ទាប់ពីចាក់ថ្នាំ ហើយបន្តមានរយៈពេល 1 ឬ 2 ថ្ងៃ។

**បញ្ហាកាន់តែធ្ងន់ធ្ងរ** បន្ទាប់ពីចាក់ថ្នាំបង្ការ រួមមាន ដូចតទៅ៖

- អាចកើនឡើងនូវហានិភ័យកើតជំងឺ Guillian-Barré (ហៅថា ជំងឺ GBS) បន្ទាប់ពីទទួលថ្នាំបង្ការអសកម្ម។ ហានិភ័យត្រូវបានគេប៉ាន់ប្រមាណថាកើតឡើងក្នុងករណី 1 ឬ 2 បន្ថែម ក្នុងចំណោមមនុស្ស 1 លាននាក់ ដែលទទួលថ្នាំបង្ការ។ ករណីនេះអាចមានកម្រិតទាបខ្លាំងជាហានិភ័យកើតជំងឺធ្ងន់ធ្ងរផ្សេងដោយសារតែជំងឺគ្រុនផ្តាសាយ ដែលអាចបង្ការបានដោយថ្នាំបង្ការជំងឺគ្រុនផ្តាសាយ។
- កុមារ ដែលចាក់ថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ព្រមគ្នានឹងថ្នាំបង្ការរោគរលាកសួត (PCV13) និង/ឬថ្នាំបង្ការខាន់ស្លាក់ តេតាណុស និងក្អកមាន់ ក្នុងពេលតែមួយ អាចនឹងកើតរោគប្រកាច់ ដោយសារតែគ្រុនក្តៅ។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីបានព័ត៌មានបន្ថែម។ សូមប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើកុមារ ដែលទទួលថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ធ្លាប់កើតរោគប្រកាច់។

**បញ្ហាដែលអាចកើតកើត បន្ទាប់ពីចាក់ថ្នាំបង្ការ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្រ្ត រាប់ទាំងការចាក់ថ្នាំបង្ការ។ ការអង្គុយ ឬតម្រេតខ្លួនប្រហែល 15 នាទី អាចជួយការពារចំពោះការសន្លប់ និងរបួសដោយសារតែការដួល។ សូមប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកវិលមុខ ឬចុក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងរោទ៍ក្នុងត្រចៀក។
- មនុស្សមួយចំនួនរមានការឈឺចុកចាប់ខ្លាំងលើស្មារ ហើយពិបាកក្នុងការធ្វើចលនាដៃ ដែលគេចាក់ថ្នាំ។ បញ្ហានេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយអាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មដោយសារថ្នាំបង្ការទាំងនោះ កម្រមានណាស់ ដែលត្រូវបានគេប៉ាន់ប្រមានថា មានប្រហែលតិចជាង 1 ក្នុងមួយលានដូស ហើយកើតឡើងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីទទួលថ្នាំបង្ការ។

ដូចថ្នាំណាក៏ដោយ មានឱកាសតិចតួចបំផុត ដែលថ្នាំបង្ការបង្ករបួសធ្ងន់ធ្ងរ ឬបណ្តាលឱ្យស្លាប់បាត់បង់ជីវិត។

គេតែងតែតាមដានពីសុវត្ថិភាពនៃថ្នាំបង្ការជានិច្ច។ ទាក់ទងនឹងព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**។

Translation provided by Shoo the Flu

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រុងប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រុងប្រយ័ត្នចំពោះបញ្ហាដែលធ្វើឱ្យលោកអ្នកព្រួយបារម្ភ ដូចជារោគសញ្ញាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  រោគសញ្ញានៃប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមមាន បន្ទាលត្រអាក ហើមមុខ និងកពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងខ្សោយ។ រោគសញ្ញាទាំងនេះអាចចាប់ផ្តើមប៉ុន្មាននាទី ដល់ប៉ុន្មានម៉ោង បន្ទាប់ពីទទួលថ្នាំបង្ការ។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើអ្នកគិតថា វាជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬបញ្ហាសង្គ្រោះបន្ទាន់ដែលមិនអាចរង់ចាំបាននោះ សូមទូរស័ព្ទទៅ 9-1-1 ហើយយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់អ្នក។
- ប្រតិកម្មគួររាយការណ៍ក្នុង Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ពីផលអាក្រក់ដោយសារថ្នាំបង្ការ)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចបញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចធ្វើដោយខ្លួនឯងតាមរយៈវិបសាយ VAERS នៅ **www.vaers.hhs.gov.** ឬទូរស័ព្ទមកលេខ **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្រ្តទេ។*

## 6 កម្មវិធីជាតិផ្តល់សំណងរបួសដោយសារតែថ្នាំបង្ការ

កម្មវិធីជាតិផ្តល់សំណងរបួសដោយសារតែថ្នាំបង្ការ (National Vaccine Injury Compensation Program, VICP) គឺជាកម្មវិធីរដ្ឋសហព័ន្ធ ដែលបានបង្កើតឡើង ដើម្បីបង់សំណងដល់អ្នកដែលអាចរងរបួសដោយសារតែថ្នាំបង្ការមួយចំនួន។

អ្នក ដែលជឿជាក់ថា ខ្លួនអាចរងរបួសដោយសារតែថ្នាំបង្ការ អាចសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារ ដោយហៅទូរស័ព្ទទៅលេខ **1-800-338-2382** ឬចុះទៅកាន់វិបសាយ VICP **www.hrsa.gov/vaccinecompensation** ។ មានពេលកំណត់សម្រាប់ដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមដោយរបៀបណា?

- សូមសួរអ្នកថែទាំសុខភាពរបស់អ្នក។ គាត់អាចផ្តល់នូវកញ្ចប់ព័ត៌មានថ្នាំបង្ការ ឬណែនាំពីប្រភពព័ត៌មានដទៃទៀត។ 1-888-767-4687
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមទាក់ទង Center for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ជំងឺ)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅកាន់វិបសាយ CDC នៅ www.cdc.gov/flu

---

Vaccine Information Statement
Inactivated Influenza Vaccine

Office Use Only

08/07/2015 Khmer

42 U.S.C. § 300aa-26
DCH-0457CA AUTH: P. H. S., Act 42, Sect. 2126.

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ព័ត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។